**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## កិច្ចប្រជុំលើកទី២៧ នៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់

គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ រៀបចំកិច្ចប្រជុំលើកទី២៧ នៅថ្ងៃអង្គារ ៥កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ នៅសណ្ឋាគារសុខាភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តមវេជ្ជបណ្ឌិត អ៊ុឹង គីរុន** រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ តំណាងឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ក្នុងគោលបំណងដើម្បីធ្វើបច្ចុប្បន្នភាពនៃការអនុវត្តការងារត្រួតពិនិត្យផលិតផលថ្នាំជក់នៅកម្ពុជា និងពិភាក្សាជំរុញការអនុវត្តទីក្រុងគ្មានផ្សែងបារី នៅថ្នាក់ក្រោមជាតិ តាមបណ្តាស្ថាប័ន ក្រសួង មន្ទីរពាក់ព័ន្ធ ឲ្យកាន់តែប្រសើរទៀត។

ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងការការពារសុខភាពប្រជាជនពីគ្រោះថ្នាក់ នៃផ្សែងផលិតផលថ្នាំជក់ គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ដែលដឹកនាំដោយក្រសួងសុខាភិបាលបានយកចិត្តទុកដាក់អនុវត្តការងារត្រួតពិនិត្យផលិតផលថ្នាំជក់សម្រេចបានជោគជ័យជាច្រើន។ ចាប់តាំងពីឆ្នាំ២០១៥ ព្រះរាជាណាចក្រកម្ពុជា មានច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ដែលបានចូលជាធរមាន ក្រសួងសុខាភិ-បាល ក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមជាតិបានសហការជំរុញការងារត្រួតពិនិត្យផលិតផលថ្នាំជក់ដោយអនុវត្តវិធានការច្បាប់ និងវិធានការអប់រំផ្លាស់ប្តូរឥរិយាបថ។ ការអនុវត្តអនុក្រឹត្យស្តីពី វិធានការហាមជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ និងទីកន្លែងសាធារណៈដែលចូលជាធរមាននៅខែកញ្ញា ឆ្នាំ២០១៦ មកម្ល៉េះ ការអនុវត្តកន្លែងធ្វើការ និងទីកន្លែងសាធារណៈគ្មានផ្សែងថ្នាំជក់នេះមានភាពរីកចម្រើនជាបន្តបន្ទាប់ដោយបានផ្លាស់ប្តូរឥរិយាបថរបស់អ្នកជក់ថ្នាំជក់ និងម្ចាស់ទីតាំង ពីទម្លាប់ជក់បារីនៅកន្លែងធ្វើការ និងទីកន្លែងសាធារណៈ។ ថ្នាក់ក្រោមជាតិបានចងក្រងជាបណ្តាញសម្ព័ន្ធទីក្រុងគ្មានផ្សែងថ្នាំជក់ចូលរួមយ៉ាងសស្រាក់សស្រាំជំរុញការអនុវត្តទីកន្លែងធ្វើការ និងទីកន្លែងសាធារណៈគ្មានផ្សែងផលិតផលថ្នាំជក់។ ទន្ទឹមនឹងនេះ ក្រសួងពាក់ព័ន្ធក៏បានខិតខំជំរុញការអនុវត្តទីកន្លែងធ្វើការ និងទីកន្លែងសាធារណៈគ្មានផ្សែងផលិតផលថ្នាំជក់នៅតាមខ្សែបណ្តោយ ដូចជា ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងកិច្ចការនារី ក្រសួងធម្មការនិងសាសនា ក្រសួងទេសចរណ៍ បានជំរុញការងារនេះ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងបរិស្ថាន ជាដើម បានបញ្ចូលការងារអប់រំផ្សព្វផ្សាយអំពីផលប៉ះពាល់ថ្នាំជក់ ព្រមទាំងជំរុញការអនុវត្តទីកន្លែងធ្វើការនិងទីកន្លែងសាធារណៈគ្មានផ្សែងផលិតផលថ្នាំជក់។



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

កិច្ចប្រជុំថ្ងៃនេះ ពិភាក្សា និងកំណត់ការងារជាអាទិភាពដើម្បីពង្រឹងការអនុវត្តវិធានការហាមជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ ឬទីកន្លែងសាធារណៈ ព្រមទាំងការជំរុញការអប់រំផ្សព្វផ្សាយបន្ថែមទៀតដើម្បីផ្លាស់ប្តូរឥរិយាបថប្រជាជនប្រកបដោយសុខភាព។ **ឯកឧត្តមវេជ្ជបណ្ឌិត អ៊ឹង ភីរុន** រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ បានលើកឡើងផងដែរថា ការងារត្រួតពិនិត្យផលិតផលថ្នាំជក់ មានវិធានការអប់រំសុខភាព និងវិធានការផ្លូវច្បាប់។ ដោយឡែកវិធានការផ្លូវច្បាប់យើងបានដោះស្រាយមួយចំនួនហើយ ដែលធ្វើឲ្យក្រុមហ៊ុនថ្នាំជក់មានការរាងចាល។ អង្គប្រជុំនាថ្ងៃនេះគឺយើងពង្រឹងការអប់រំសុខភាពបន្ថែមទៀត អំពីគ្រោះថ្នាក់ នៃការប្រើប្រាស់ផលិតផលថ្នាំជក់នេះ ជាពិសេសនៅតាមរថយន្តដែលផ្ទុកអ្នកដំណើរច្រើន តាមសណ្ឋាគារ ភោជនីយដ្ឋាន ទីកន្លែងធ្វើការ និងទីកន្លែងសាធារណៈ យើងនឹងជំរុញអនុវត្តបន្ថែមទៀត។

ក្រសួងសុខាភិបាល សូមអំពាវនាវដល់សាធារណជនគ្រប់រូបដែលកំពុងប្រើប្រាស់ផលិតផលថ្នាំជក់ សូមលះបង់ទម្លាប់ប្រើប្រាស់ផលិតផលថ្នាំជក់ និងអ្នកដែលមិនទាន់ចាប់ផ្តើមប្រើប្រាស់ផលិតផលថ្នាំជក់ សូមចៀសវាងពីការប្រើប្រាស់ផលិតផលថ្នាំជក់ ដើម្បីសុខភាពរបស់យើង និងសូមអំពាវនាវដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ចូលរួមអនុវត្ត និងជំរុញការអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ឲ្យមានប្រសិទ្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។

ប្រសិនបើមានបំណងចង់ទទួលការផ្តល់ប្រឹក្សាលះបង់ទម្លាប់ប្រើប្រាស់ផលិតផលថ្នាំជក់ សូមទំនាក់ទំនងតាមរយៈទូរសព្ទលេខ ០១៧ ៧៩២ ៤០៧។

ថ្ងៃអង្គារ ៥កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២